ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ០៣៩ MOC / SM 2010

# សារាចរណែនាំ
## ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផល
## ដែលបានវេចខ្ចប់ចំរុះគ្នាលក់ជាវត្ថុអនុស្សាវរីយ៍

កន្លងមកអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហ័រណ-អាហ័រណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម បានធ្វើការអង្កេត និងត្រួតពិនិត្យទំនិញនៅលើទីផ្សារទូទាំងប្រទេសទទួលបានលទ្ធផលល្អប្រសើរ ជំរុញអោយទីផ្សារមានរបៀបរៀបរយ និងមានលក្ខណៈសមស្របតាមបញ្ញត្តិពាក់ព័ន្ធ ជាពិសេសផលិតផលម្ហូបអាហារ ។ ជាលទ្ធផលចេញពីសកម្មភាពនេះអគ្គនាយកដ្ឋានកាំកុងត្រូល មានការកត់សម្គាល់ក្នុងភាពជាក់លាក់ និងទទួលព័ត៌មានពីប្រភពនានារួមទាំងអតិថិជនផង ទំនិញចំរុះដែលក្នុងនោះមានផលិតផលម្ហូបអាហារផងដែរ ត្រូវបានវេចខ្ចប់រួមគ្នាជាកញ្ចប់, ជាកន្ត្រក ឬទំរង់ផ្សេងៗទៀតបញ្ចូលលាយឡំគ្នានូវផលិតផលខូចគុណភាព ហួសកាលបរិច្ឆេទប្រើប្រាស់ជាដើម ដាក់លក់ជាវត្ថុអនុស្សាវរីយ៍ ជាពិសេសក្នុងពេលមានពិធីបុណ្យផ្សេងៗ ។

ស្ថានភាពបែបនេះគឺជាការប្រព្រឹត្តិល្មើសនឹងច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព ផលិតផល ទំនិញ និងសេវា ការពារអ្នកប្រើប្រាស់ ហើយក៏គឺជាការទាក់ទាញអារម្មណ៍មហាជនអំពីកង្វះសីលធម៌ក្នុងការប្រកបអាជីវកម្ម ទៀតផង ។

ដើម្បីកំណត់អោយជាក់លាក់នូវបន្ទុកទទួលខុសត្រូវផ្នែកច្បាប់ ចំពោះបាតុភាពខុសឆ្គង ពីភាពមិនសមស្របនៃផលិតផលដែលវេចខ្ចប់រួមគ្នាជាវត្ថុអនុស្សាវរីយ៍ ក្រសួងពាណិជ្ជកម្មសូមធ្វើការណែនាំដូចតទៅ ៖

១. កញ្ចប់ ឬកន្ត្រក ដែលមានវេចខ្ចប់ស្រេចនូវផលិតផលនានាដាក់លក់ ជាវត្ថុអនុស្សាវរីយ៍ ត្រូវមានបិទស្លាកសំគាល់បញ្ជាក់នូវ ឈ្មោះ និងអាសយដ្ឋានរបស់អាជីវកម្មនៃវត្ថុអនុស្សាវរីយ៍ វេចខ្ចប់នោះ ។

២. ត្រូវចេញវិក័យប័ត្រតាមទម្រង់ប្រើប្រាស់ជាផ្លូវការរបស់គ្រឹះស្ថានអាជីវកម្ម និងមានខ្លឹមសារជាក់លាក់ និងត្រឹមត្រូវផ្តល់ជូនអតិថិជន ។

អនុលោមទៅតាម ខ្លឹមសារនៃសារាចរណែនាំនេះក្រសួងពាណិជ្ជកម្ម មានទំនុកចិត្តយ៉ាងមុតមាំថានឹងទទួលបាននូវកិច្ចសហការប្រកបដោយប្រសិទ្ធិភាព ពីអាជីវកម្មពាក់ព័ន្ធ អតិថិជន និងប្រជាពលរដ្ឋជាក់ជាពុំខាន ។

អគ្គនាយកដ្ឋានកាំកុងត្រូល ត្រូវឃ្លាំពិនិត្យនូវការកែលំអរនេះ ដោយសហការជាមួយគ្រប់ភាគីពាក់ព័ន្ធឈរលើស្មារតីទទួលខុសត្រូវ ធានានូវការសម្របសម្រួលឱ្យការធ្វើអាជីវកម្មមានភាពស្មោះត្រង់ និងធានាបាននូវសុខមាលភាពប្រជាពលរដ្ឋ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន</u>** :

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងព័ត៌មាន (ដើម្បីសហការផ្សព្វផ្សាយ)
- អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហ័រណ-អាហ័រណ និងបង្ក្រាបការក្លែងបន្លំ “ កាំកុងត្រូល ” (ដើម្បីអនុវត្ត)
- គ្រប់សាលាខេត្ត-រាជធានី (ដើម្បីសហការអនុវត្ត)
- សភាពាណិជ្ជកម្មខេត្ត- រាជធានី (ដើម្បីគោលដៅជាប្រយោជន៍)
- ឯកសារ - កាលប្បវត្តិ